35/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

តាងនាមប្រជារាស្ត្រខ្មែរ
សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៖ ៤៤៧
ចុះថ្ងៃទី០៣-៩-២០០៨
សាលដីកា
លេខ ៖ ៣៣ "ក្រ"
ចុះថ្ងៃទី០៦-០៧-២០១១

បានបង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទី ០៦-៧-២០១១ ដោយមានសមាសភាពដូចខាងក្រោម ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សា

- លោក [redacted] ជាចៅក្រមប្រឹក្សា

- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៤៤៧ ចុះថ្ងៃទី០៣-៩-២០០៨ ដែលមាន ៖

-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅសង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានទីលំនៅសព្វថ្ងៃស្នាក់នៅផ្ទះជួល សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] មានកូន ០៣នាក់ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ស) ទោសពីមុន គ្មាន ។

<u>ជាប់ចោទពីបទ</u> ៖ ប្លន់ ប្រព្រឹត្តនៅសង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ





Scanned by CamScanner

កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

**-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]**ភេទស្រី អាយុ ២១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វផ្ទះលេខ ១០៣ ផ្លូវលេខ ១៣៨ ក្រុមទី៦ សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**៦រឿងហេតុមានដូចតទៅ ៖**

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៧-៦-២០០៧ របស់ឈ្មោ[redacted]បានបញ្ជាក់ថា: នៅថ្ងៃទី ២៧-៦-២០០៧ វេលាម៉ោង ១១:៣០នាទី ឈ្មោះ[redacted]បានមកពីរៀននៅសកលវិទ្យាល័យ បានទុកម៉ូតូនៅមុខផ្ទះលេខ ៣៧៣ ហាងកែសម្ផស្ស ល្អពិត ផ្លូវម៉ៅសេទុង សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក លុះដល់ម៉ោង ១៤:០០នាទី ឈ្មោ[redacted]ចេញពីរៀនវិញ ក៏ទើបដឹងបាត់ម៉ូតូតែម្តង ។

**-បានឃើញ សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ២២ "ក្រ២" ចុះថ្ងៃទី១៩-៣-២០០៨ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖**

១-ផ្តន្ទាទោសលើឈ្មោ[redacted]ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ **៥ឆ្នាំ (ប្រាំឆ្នាំ)** គិតបន្តពីសាលក្រមមុន ពីបទ: **ប្លន់** ប្រព្រឹត្តនៅសង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-ឲ្យឈ្មោះ[redacted] សងទៅឈ្មោះ[redacted]ជាដើមបណ្តឹង នូវសំណងថ្លៃម៉ូតូ ម៉ាក់ ហុងដា ធុន គុបសេ ៥០ ចង្កៀងជ្រុង ចំនួន មួយគ្រឿង គិតជាប្រាក់រៀលស្មើនិងប្រាក់អាមេរិកចំនួន **៩០០$ (ប្រាំបួនរយដុល្លាអាមេរិក)** និងសងសំណងជំងឺចិត្ត គិតជាប្រាក់រៀល ស្មើនឹងប្រាក់អាមេរិកចំនួន **២០០$ (ពីររយដុល្លាអាមេរិក )** ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។ ទុករយៈពេលប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោ[redacted] (អវត្តមាន)

-មេធាវីលោក[redacted]ការពារជនជាប់ចោទ (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted] (អវត្តមាន)



Scanned by CamScanner

**សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ** :

សុំតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

-មេធាវីលោក[redacted]ការពារអោយជនជាប់ចោទឈ្មោះ[redacted]បាន ធ្វើសេចក្តីសន្និដ្ឋានថា: តាមការពិនិត្យសំណុំរឿង បទល្មើសនេះជាបទល្មើសមជ្ឈិម មិនមែនជាបទល្មើសប្លន់នោះទេ គឺគាត់លួចតែម្នាក់ឯង ហើយដោយស្ងៀមស្ងាត់ទៀតផង ហេតុនេះសុំប្រធានក្រុមប្រឹក្សាមេត្តាកែប្រែបទចោទ យោងតាមមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងឯកសារនានា

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**សាលាឧទ្ធរណ៍**

**យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍លេខ ១១៩ ចុះថ្ងៃទី ២៨-៣-២០០៨ របស់ជនជាប់ចោទឈ្មោះ[redacted]ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២២ (ក្រ២) ចុះថ្ងៃទី ១៩-៣-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះយកមកជំនុំជម្រះបានតាមច្បាប់ ។

២-ជនជាប់ចោទឈ្មោះ[redacted]ពិតជាបានប្រើប្រាស់ប្រដាប់កាច់សោរកម៉ូតូ និងកូនសោរលេខ ៨ កាច់បំបែកគ្រាប់សោរកម៉ូតូ និងយកម៉ូតូបានសម្រេច ហើយអំពើនេះជាអំពើលួចប្រើហិង្សា ។

៣-សាលក្រមព្រហ្មទណ្ឌលេខ ២២ ក្រ២ ចុះថ្ងៃទី១៩-៣-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវហើយ គ្រាន់តែសាលាឧទ្ធរណ៍បន្ថយទោសខ្លះតាមច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ១១៩ ចុះថ្ងៃទី ២៨-៣-២០០៨ របស់ជនជាប់ចោទឈ្មោះ[redacted]ពិតជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២២ "ក្រ២" ចុះថ្ងៃទី ១៩-៣-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបាន លើកលែងតែផ្តន្ទាទោសត្រូវកែប្រែមកជាផ្តន្ទាទោសកំណត់



Scanned by CamScanner

[redacted]វិញ ក្រៅពីនេះរក្សាទុកដដែល ។

៣-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី០៦-៧-២០១១ ចំពោះមុខមេធាវីការពារជនជាប់ កំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី..១៩......ខែកក្កដា ឆ្នាំ២០11.

**ក្រឡាបញ្ជី**

[redacted]



Scanned by CamScanner